ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តកំពង់ស្ពឺ**

លេខ៖...២៤០......សជណ/ផអ៣

កំពង់ស្ពឺ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង
# ស្តីពី
# ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៧

រដ្ឋបាលខេត្តកំពង់ស្ពឺ សូមជម្រាបជូនដំណឹងដល់លោក លោកស្រី ជាប្រធានក្រុមហ៊ុនទទួលការទាំងក្នុង និងក្រៅខេត្តទាំងអស់ ឱ្យបានជ្រាបថាៈ រដ្ឋបាលខេត្តកំពង់ស្ពឺ នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៧ សម្រាប់ចូលរួមដេញថ្លៃគម្រោងមូលនិធិឃុំសង្កាត់ ឆ្នាំ ២០១៧។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ មានសិទ្ធិដាក់សំណើដេញថ្លៃគ្រប់គម្រោងមូលនិធិឃុំសង្កាត់ ទាំងអស់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា ៣ ប្រភេទ៖

- ប្រភេទទី ១ ៖ អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អាគារ និងការងារបេតុង។ល។)
- ប្រភេទទី ២ ៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវគ្រួសក្រហម។ល។)
- ប្រភេទទី ៣ ៖ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារ ពិសេស ឧទាហរណ៍. អណ្តូងស្នប់។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងនឹងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច២ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ នឹងចុះពិនិត្យដល់ទីតាំង ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការ របស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិ នឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យ និងសម្រេច។ អ្នកទទួលការទាំងឡាយណា ដែលត្រូវបានរកឃើញថាមានការពាក់ព័ន្ធនឹងការឃុបឃិតស៊ុំគ្រលំគ្នា ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបាន ដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើលោក លោកស្រី ប្រធានក្រុមហ៊ុនទទួលការ មានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគ នៃសាលាខេត្តកំពង់ស្ពឺ ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ វេលាម៉ោង ១៧:៣០នាទី។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការ និងវិនិយោគ ដោយឥតបង់ថ្លៃ តាមអាសយដ្ឋានស្ថិតក្នុងបរិវេណសាលាខេត្តកំពង់ស្ពឺ អាគារខាងត្បូង រៀងរាល់ម៉ោងធ្វើការ ឬអាចទាញយកពីក្នុងគេហទំព័ររបស់ គ.ជ.អ.ប។

**អភិបាលខេត្ត**

**ខ៊ុំ សំណាង**